ពិធីការបើកឡើងវិញសម្រាប់រោងភាពយន្តបើកចូល

បច្ចុប្បន្នភាពថ្មីៗ

9/17/20៖ ពិធីការត្រូវបានពង្រីកដើម្បីដោះស្រាយពីរោងភាពយន្តបើកចូលពាក់កណ្តាលអចិន្ត្រៃយ៍ និងបណ្តោះអាសន្នដោយមានផ្នែកមួយនៅចុងបញ្ចប់សម្រាប់រោងភាពយន្តទាំងនេះជាពិសេស។ ព្រឹត្តិការណ៍បើកចូលផ្ទាល់ (ឧ. ការប្រគុំតន្ត្រី ការសម្តែងផ្ទាល់មិនត្រូវបានអនុញ្ញាតឡើយ។ បានផ្តល់ការបញ្ជាក់ទាក់ទងនឹងការផ្តល់ម្ហូបអាហារ។ បុគ្គលម្នាក់ៗត្រូវតែស្ថិតនៅក្នុង ឬលើយានយន្តរបស់ខ្លួន។ រថយន្តដែលអាចបំប្លែងបាន អាចទម្លាក់ដំបូលរបស់ខ្លួន ហើយអ្នកទស្សនាអាចអង្គុយនៅផ្នែកខាងក្រៅនៃយានយន្តរបស់ខ្លួន (ឧ. ឃ្លុបក្រោយនៃរថយន្តប្រភេទភីកអាប់)។

10/4/20៖ បទពិសោធន៍បើកចូលផ្ទាល់នៅខាងក្រៅអគារ ដូចជាការប្រគុំតន្ត្រី និងការសម្តែង ត្រូវបានអនុញ្ញាតក្រោមពិធីការនេះ ដរាបណាមានការអនុលោមតាមពិធីការសម្រាប់តន្ត្រី ទូរទស្សន៍ និងការផលិតភាពយន្តផងដែរ។

ពិធីការនេះអនុវត្តទាំងលើអាជីវកម្ម និងប្រតិបត្តិការរោងភាពយន្តបើកចូលថ្មីៗ។ ប្រតិបត្តិការភាពយន្តបើកចូលទាំងអស់ ត្រូវតែមានហេដ្ឋារចនាសម្ព័ន្ធ បុគ្គលិក និងការបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីឆ្លើយតបតាមសេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយ របាំងមុខ និងអនាម័យទាំងអស់។ ទីកន្លែងដែលមានកម្លាំងពលកម្មបន្ទប់ទឹក និងទីកន្លែងចំណីអាហារដែលបានបង្កើតរួចជាស្រេច គឺអាចឆ្លើយតបតាមសេចក្តីតម្រូវសុវត្ថិភាពកាន់តែងាយស្រួល។ សេចក្តីតម្រូវដែលជាក់លាក់ចំពោះប្រតិបត្តិការបើកចូលថ្មីៗដែលកំពុងត្រូវបានរៀបចំនៅក្នុងចំណតយានយន្ត និងទីកន្លែងផ្សេងៗទៀតដែលមិនមានអាជីវកម្មភាពយន្តបើកចូលពីមុនមក គឺត្រូវបានរៀបរាប់នៅចុងបញ្ចប់នៃពិធីការនេះ។

ប្រតិបត្តិការភាពយន្តបើកចូល ត្រូវតែស្ថិតក្រោមការគ្រប់គ្រងដោយនិយោជកតែម្នាក់ដែលទទួលបន្ទុកលើទីកន្លែងនោះ ដែលនឹងទទួលខុសត្រូវលើការបណ្តុះបណ្តាលជាបន្ត និងការត្រួតពិនិត្យបុគ្គលិកទាំងអស់ ការផ្តល់បរិក្ខារ និងសម្ភារៈដែលចាំបាច់ទាំងអស់ ការត្រួតពិនិត្យការអនុវត្តតាមវិធានការណ៍សុវត្ថិភាពទាំងអស់ក្នុងអំឡុងពេលកំពុងចាក់បង្ហាញណាមួយ និងការទទួលការអនុញ្ញាតពីមន្ត្រីរៀបចំតំបន់តាមមូលដ្ឋាន និងមន្ត្រីក្រុង បើចាំបាច់។

រោងភាពយន្តបើកចូល អាចបញ្ចាំងខ្លឹមសារដែលបានស្នើមផ្ទាល់ ដែលត្រូវបានថតនៅកន្លែងផ្សេង ដរាបណាការថតគោរពតាម សេចក្តីតម្រូវដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងឧបសម្ព័ន្ធ J។

សេវាកម្មម្ហូបអាហារទាំងឡាយ ត្រូវតែមកពីភោជនីយដ្ឋានដែលមានអាជ្ញាប័ណ្ណនៅនឹងកន្លែង តូបលក់អាហារសម្រន់ដែលបានអនុញ្ញាត ឬម្ហូបអាហារដែលបានវេចខ្ចប់ជាមុនពីទីផ្សារដែលបានអនុញ្ញាតដោយអង្គភាពសុខភាពបរិស្ថាន។ គេអាចទិញ និងមកយកម្ហូបអាហារនៅនឹងកន្លែង ឬបញ្ជាទិញតាមរយៈសេវាដឹកជញ្ជូនភាគីទីបី និងដឹកជញ្ជូនទៅដល់យានយន្តរបស់អតិថិជន។ ទីកន្លែងម្ហូបអាហារទាំងនេះ ត្រូវតែគោរពតាមពិធីការបើកឡើងវិញនៃភោជនីយដ្ឋាន និង/ឬសេវាកម្មម្ហូបអាហារជាធរមាន។ អ្នកចូលរួមអាចយកម្ហូបអាហាររបស់ខ្លួនមកបាន។ តូបលក់អាហារសម្រន់បណ្តោះអាសន្ន និងទីកន្លែងម្ហូបអាហារផ្សេងទៀត (ឧ. ម្ហូបអាហារដែលបានផ្ទត់ផ្ទង់ រថយន្តលក់ម្ហូបអាហារ ទេះលក់ម្ហូបអាហារ) មិនត្រូវបានអនុញ្ញាតទេ។

ពិធីការនេះក៏អាចត្រូវបានប្រើសម្រាប់បទពិសោធន៍បើកចូលខាងក្រៅអគារផ្សេងទៀត ដូចជាការប្រគុំតន្ត្រី និងការសម្តែងផងដែរ ដរាបណាមានការអនុលោមតាមពិធីការសម្រាប់តន្ត្រី ទូរទស្សន៍ និងការផលិតភាពយន្តដែលបានចុះផ្សាយបន្ថែមលើការណែនាំដែលបានកត់សម្គាល់ខាងក្រោម។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យអាជីវកម្មលក់រាយបើកទ្វារឡើងវិញដោយសុវត្ថិភាព។ សេចក្តីតម្រូវខាងក្រោមគឺជាក់លាក់សម្រាប់រោងភាពយន្តបើកចូល ដែលត្រូវបានអនុញ្ញាតឲ្យបើកដំណើរការឡើងវិញក្រោមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាល។ បន្ថែមលើលក្ខខ័ណ្ឌដែលបានដាក់ចុះទៅលើអាជីវកម្មទាំងនេះដោយមន្ត្រីសុខាភិបាលសាធារណៈរដ្ឋ អាជីវកម្មភាពយន្តបើកចូលក៏ត្រូវអនុវត្តតាមលក្ខខ័ណ្ឌដែលបានចែងនៅក្នុងបញ្ជីត្រួតពិនិត្យសម្រាប់រោងភាពយន្តបើកចូល (Checklist for Drive-in Movie Theaters) នេះផងដែរ។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំ សម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក
(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ
(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ
(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណជន
(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយ ស្របពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

អាជីវកម្មទាំងអស់ដែលត្រូវបានគ្របដណ្តប់ដោយការណែនាំនេះ ត្រូវតែដាក់ចុះនូវវិធានការណ៍ដែលអាចអនុវត្តបានទាំងអស់ ដែលមានរាយនៅខាងក្រោម និងត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុនៃវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្ត គឺមិនអាចអនុវត្តបានសម្រាប់អាជីវកម្ម។

ឈ្មោះអាជីវកម្ម៖ _____

អាសយដ្ឋានទីកន្លែង៖ _____

កាលបរិច្ឆេទចុះផ្សាយ៖ _____

កំណត់សម្គាល់៖ នៅក្នុងពិធីការនេះ ពាក្យ "រថយន្ត" ត្រូវបានប្រើដើម្បីចង្អុលបង្ហាញពីរថយន្ត រថយន្តដឹកទំនិញ រថយន្តកាម្មុងតូចៗ រថយន្តបោះតង់ ឬយានយន្តផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការដឹកជញ្ជូនឯកជន។ ទីកន្លែងអាចដាក់កម្រិតលើប្រភេទ ឬទំហំនៃយានយន្តដែលត្រូវបានអនុញ្ញាត តាមការចាំបាច់។

A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្ត សម្រាប់ទីកន្លែង)

- ☐ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ☐ បុគ្គលិកដាយរងគ្រោះ (អ្នកដែលមានអាយុលើ 65 ឆ្នាំ អ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ☐ បុគ្គលិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកទទួលប្រាក់ឈ្នួល អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត ត្រូវបានសំដៅជារួមថា "បុគ្គលិក") ត្រូវបានប្រាប់ថាកុំមកធ្វើការបើសិនជាឈឺ ឬបើសិនជាពួកគេបានប៉ះពាល់ជាមួយបុគ្គលដែលមានជំងឺ COVID-19។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
  - ☐ បុគ្គលិកបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍នៃការសុំច្បាប់ឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្ទៃកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ មើលព័ត៌មានបន្ថែមស្តីពី កម្មវិធី រដ្ឋាភិបាលដែលគាំទ្រការសុំច្បាប់ឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិក

ក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគក្អរ៉ូណាដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act) និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួលអត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋាននៃភាពទាក់ទងនឹងការងាររបស់ជំងឺ COVID-19 ដែលកើតឡើងចន្លោះថ្ងៃទី 19 ខែមីនា និងថ្ងៃទី 5 ខែកក្កដា ដោយអនុលោមតាម បទបញ្ញត្តិប្រតិបត្តិលេខ N-62-20 របស់អភិបាលរដ្ឋ។

- ☐ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិកធ្វើការងារពីផ្ទះ។
- ☐ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដូចគ្នា ជាមួយជំងឺ COVID-19 (ករណី) និយោជកមានផែនការដើម្បីឲ្យករណីដាក់ខ្លួនឲ្យដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យដាក់ខ្លួននៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិកទាំងអស់ដែលបានប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ ផែនការរបស់និយោជកគួរពិចារណាអំពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ឲ្យទទួលឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែម ដែលអាចតម្រូវឲ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែមឬក៏អត់។ មើលការណែនាំសុខភាពសាធារណៈនៅក្នុង ការឆ្លើយតបនឹងជំងឺ COVID-19 នៅក្នុងកន្លែងធ្វើការ។
- ☐ ការត្រួតពិនិត្យបុគ្គលិក ក្រុមថត តន្ត្រីករ និងអ្នកសម្តែង ត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចនឹងចូលមកកាន់កន្លែងធ្វើការ។ ការត្រួតពិនិត្យ ត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអាការក្តុនក្តៅឬក្តុនរងា និងថាតើបុគ្គលិកបានប៉ះពាល់ជាមួយបុគ្គលដែលត្រូវបានគេដឹងថាបានឆ្លងជំងឺ COVID-19 ក្នុងរយៈពេល 14 ថ្ងៃចុងក្រោយឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានពីចម្ងាយ ឬដោយផ្ទាល់នៅពេលបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
- ☐ នៅក្នុងករណីដែលរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកគួររាយការណ៍ពីចង្អោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាចង្អោមត្រូវបានរកឃើញនៅកន្លែងការងារ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបនឹងការឆ្លងជាចង្អោមដែលរួមមានការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្របច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់តាមតំបន់។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈនឹងត្រូវបានចាត់តាំងសម្រាប់ធ្វើការស៊ើបអង្កេតលើចង្អោមនេះ ដើម្បីជួយដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ☐ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃទទួលបានរបាំងមុខសមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខនេះគ្រប់ពេលវេលាក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំង មុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់រុំពីគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ញត្តិរបស់រដ្ឋ ដរាបណាស្ថានភាពសុខភាពរបស់ពួកគេអនុញ្ញាតឲ្យធ្វើដូច្នេះ។ ក្រណាត់រុំដែលមានទម្រង់រឹតតឹងខាងក្រោមចង្អាគឺជាការល្អ។ មិនគួរប្រើម៉ាស់ដែលមានវ៉ាល់មួយផ្លូវ ឬឡើយ។ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯង នៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។
- ☐ បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ឬផ្លាស់ប្តូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- ☐ ស្ថានីយការងារ ឬទីកន្លែងធ្វើការទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិចប្រាំមួយហ្វីត។
- ☐ បន្ទប់លក់សំបុត្រ ទីកន្លែងលក់ម្ហូបអាហារ បន្ទប់សម្រាករបស់បុគ្គលិក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគជាញឹកញាប់ទៅតាមកាលវិភាគដូចខាងក្រោម៖
  - ☐ បន្ទប់លក់សំបុត្រ _____
  - ☐ ទីកន្លែងលក់អាហារសម្រន់_____
  - ☐ បន្ទប់សម្រាក _____
  - ☐ បន្ទប់ទឹក _____
  - ☐ ផ្សេងទៀត _____
- ☐ ការសម្រាកត្រូវបានកំណត់ដាច់ៗពីគ្នាដើម្បីប្រាកដថាបុគ្គលិកអាចរក្សាគំលាតប្រាំមួយ (6) ហ្វីតពីគ្នានៅក្នុងបន្ទប់សម្រាកនៅគ្រប់ពេលវេលា។

- ☐ បុគ្គលិកត្រូវបានហាមឃាត់មិនឲ្យបរិភោគ ឬផឹកនៅកន្លែងណាមួយនៅក្នុងកន្លែងធ្វើការក្រៅពីទីកន្លែងសម្រាកដែលបានកំណត់ឡើយ។
- ☐ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់ឲ្យបុគ្គលិកនៅទីតាំងដូចខាងក្រោម៖

  _____
- ☐ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

  _____
- ☐ បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកឲ្យបានញឹកញាប់ដើម្បីលាងដៃរបស់ខ្លួន។
- ☐ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- ☐ កម្មករនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងលំហធ្វើការដែលបានកំណត់។ ការប្រើប្រាស់រួមគ្នានូវវត្ថុដែលបានប៉ះរួច ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- ☐ គោលការណ៍ទាំងអស់ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងលក្ខខ័ណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំង នោះក្នុងនាមជាភាគីទីបី។
- ☐ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតពិត

- ☐ ប្រព័ន្ធប្រតិបត្តិការដោយមិនប្រើសាច់ប្រាក់ និងមិនប៉ះត្រូវបានអនុវត្តនៅកន្លែងដែលអាចធ្វើបាន។ ការកក់ និងការបង់ប្រាក់អាចធ្វើឡើងជាមុនតាមអនឡាញ ឬតាមទូរស័ព្ទ។
- ☐ យានយន្តត្រូវតែឃ្លាតពីគ្នាជ្រុំមួយហ្វីត និងមិនអនុញ្ញាតឲ្យមានការប្រមូលផ្តុំមនុស្សនៅខាងក្រៅយានយន្តឡើយ។ ទីធ្លាចំណតសម្រាប់ទស្សនានៅរោងភាពយន្តបើកចូល ត្រូវបានដាក់កម្រិតត្រឹមកន្លែងដែលផ្ទោះមួយ ឬត្រូវបានរៀបចំឡើងវិញដើម្បីធានាបាននូវការរក្សាគំលាតសមស្របរវាងយានយន្ត។
- ☐ យានយន្តនីមួយៗត្រូវបានដាក់កម្រិតឲ្យមានផ្ទុកតែសមាជិកនៃគ្រួសារតែមួយ ដែលបានប៉ះពាល់ជិតស្និទ្ធជាមួយគ្នារួចទៅហើយ។ បើសិនជាមិនប្រើប្រាស់បន្ទប់ទឹក ឬរកទិញអាហារសម្រន់ អតិថិជនត្រូវតែស្ថិតនៅក្នុងយានយន្តរបស់ខ្លួន។ អតិថិជនមិនអាចអង្គុយនៅខាងក្រៅយានយន្តរបស់ខ្លួន ឧ. ដើម្បីមើលភាពយន្តបើកចូលនៅជិតយានយន្តរបស់ខ្លួនបានទេ។
- ☐ រថយន្តដែលចូលត្រូវបានហាមឃាត់មិនឲ្យលើសពីចំណុះអតិបរមារបស់ខ្លួន។
- ☐ បុគ្គលម្នាក់ៗត្រូវតែស្ថិតនៅក្នុង ឬនៅលើយានយន្តរបស់ខ្លួន។ រថយន្តដែលអាចបំប្លែងបានអាចទម្លាក់ដំបូលរបស់ខ្លួន ហើយអ្នកទស្សនាអាចអង្គុយនៅផ្នែកខាងក្រៅនៃយានយន្តរបស់ខ្លួនដូចជាឃ្លីបក្រោយនៃរថយន្តភីកអាប់ជាដើម។
- ☐ បុគ្គលិកដែលពាក់ក្រណាត់ជ្រាងមុខ ត្រូវបានដាក់ឲ្យប្រចាំការដោយឃ្លាតពីអតិថិជនផ្ទាល់ជ្រុំមួយហ្វីត ដើម្បីបើកទីធ្លាចំណត។
- ☐ ស្នូនកម្សាន្តសម្រាប់កុមារ កន្លែងពិចនិក និងទីកន្លែងសម្រាប់ការកម្សាន្តរបស់មនុស្សធំ ដើម្បីមើលមុនពេលចាក់បញ្ចាំង ត្រូវបានបិទ។ អ្នកទស្សនាមិនត្រូវប្រើកន្លែងអង្គុយនៅខាងក្រៅអគារឡើយ ហើយត្រូវតែស្ថិតនៅក្នុងរថ យន្ត។ គេត្រូវតែបិទកន្លែងអង្គុយនៅខាងក្រៅអគារទាំងឡាយដែលស្ថិតក្នុងចម្ងាយ 100 ហ្វីតពីទីកន្លែងទស្សនាមួយម៉ោងមុនពេលម៉ោងចាក់បញ្ចាំង និងត្រូវបិទជាបន្តរហូតដល់កន្លងផុតមួយម៉ោងបន្ទាប់ពីការបញ្ចាំងចប់។
- ☐ បុគ្គលដែលពាក់ក្រណាត់ជ្រាងមុខ ត្រូវបានដាក់ឲ្យប្រចាំការនៅច្រកចូលទៅកាន់កន្លែងលក់អាហារសម្រន់ និងបន្ទប់ទឹកដោយស្ថិតនៅគំលាតជ្រុំមួយហ្វីតពីគ្នា និងពីអតិថិជនដែលនៅជិតបំផុត ដើម្បីធានាបាននូវការរក្សាគំលាត 6 ហ្វីតនៅក្នុងជួរ និងនៅក្នុងទីកន្លែង។
- ☐ ប្រតិបត្តិការលក់អាហារសម្រន់ដែលជាផ្នែកនៃរោងភាពយន្តបើកចូលអចិន្ត្រៃយ៍ ត្រូវបានរៀបចំឡើងវិញដើម្បីអនុញ្ញាតឲ្យមានការរក្សាគំលាតរាងកាយ។
  - ☐ បើអាចធ្វើបាន ការបញ្ជាទិញជាមុន និងការបង់ប្រាក់តាមបែបអេឡិចត្រូនិកនៅតាមម៉ោង

ដែលបានកំណត់សម្រាប់ទៅយក គឺត្រូវបានផ្តល់ជូន។

- ☐ បើសិនជាអតិថិជនត្រូវបានអនុញ្ញាតឲ្យបញ្ជាទិញ និងទៅយកនៅតូបលក់អាហារសម្រន់ ពួកគេទទួលបានម៉ឺនុយ (បានបិទផ្សាយ ឬក្រដាសចែកសម្រាប់ប្រើតែម្តង) ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ការបញ្ជាទិញ ហើយការបញ្ជាទិញទំនិញ ត្រូវបានប្រមូលវេចខ្ចប់និងយកដោយអតិថិជនក្នុងរយៈពេល 15 នាទីបន្ទាប់ពីបញ្ជាទិញនៅនឹងកន្លែង។ អតិថិជនដែលរង់ចាំទំនិញ មិនអាចប្រមូលផ្តុំនៅកន្លែងលក់អាហារសម្រន់បានទេ។ ពួកគេអាចរង់ចាំ ដោយរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីគ្នា នៅឆ្ងាយពីកន្លែងលក់អាហារសម្រន់ ឬត្រឡប់ទៅរថយន្តរបស់ខ្លួនវិញ រួចមកម្តងទៀតនៅម៉ោងដែលបានកំណត់ដើម្បីយកការបញ្ជាទិញរបស់ខ្លួន។
- ☐ បើសិនជាអតិថិជនចាំបាច់ត្រូវតម្រង់ជួរដើម្បីធ្វើការបញ្ជាទិញ ឬយកម្ហូប បង់ស្អិតឬការសម្គាល់ផ្សេងទៀតបញ្ជាក់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនដែលមកដល់ដើម្បីយកទំនិញ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលមកក្រោយៗទៀត ដែលចូលតម្រង់ជួរ។
- ☐ មិនអនុញ្ញាតឲ្យកុមារអាយុក្រោម 12 ឆ្នាំចូលទៅកន្លែងលក់អាហារសម្រន់ ឬបន្ទប់ទឹកតែម្នាក់ឯងឡើយ។
- ☐ មិនអនុញ្ញាតឲ្យមានមនុស្សធំជ្រើនជាងពីរនាក់ក្នុងមួយយានយន្ត ដើម្បីមកយកការបញ្ជាទិញម្ហូបអាហារឡើយ។ បើសិនជាមនុស្សធំម្នាក់កំពុងមកយកការបញ្ជាទិញ ពួកគេអាចមានកុមារម្នាក់មកជាមួយ។
- ☐ តូបលក់អាហារសម្រន់ ត្រូវបានបិទសម្រាប់ការបញ្ជាទិញថ្មីៗយ៉ាងតិច 30 នាទីមុនពេលការបញ្ចាំងភាពយន្តចប់។

- ☐ បន្ទប់ទឹកត្រូវបានរៀបចំឡើងវិញ ហើយចំនួនមនុស្សត្រូវបានដាក់កម្រិតដើម្បីឲ្យអាចរក្សាគំលាត 6 ហ្វីតពីគ្នាបានគ្រប់ពេលវេលា។ សេចក្តីតម្រូវ 6 ហ្វីតនេះអនុវត្តគ្រប់ករណីទាំងអស់ លើកលែងតែបុគ្គលដែលទៅជាមួយសមាជិកគ្រួសាររបស់ខ្លួន ដែលត្រូវការជំនួយ (ឧ. កុមារ ឬបុគ្គលដែលពិការ)។
- ☐ បើសិនជាអតិថិជនចាំបាច់ត្រូវការតម្រង់ជួរដើម្បីចូលទៅក្នុងបន្ទប់ទឹក បង់ស្អិតឬការសម្គាល់ផ្សេងទៀតបញ្ជាក់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនដែលមកដល់ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលមកក្រោយៗទៀត ដែលចូលតម្រង់ជួរ។
- ☐ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអតិថិជន និងពីបុគ្គលិកដូចគ្នានៅកន្លែងបញ្ជាទិញអាហារសម្រន់ កន្លែងទៅយក និងកន្លែងបង់ប្រាក់។ បុគ្គលិកអាចមកជិតជាបណ្តោះអាសន្ន នៅពេលចាំបាច់ដើម្បីទទួលយកការបង់ប្រាក់ បញ្ជូនទំនិញឬសេវាកម្ម ឬទៅតាមការចាំបាច់។
- ☐ លក្ខណៈពិសេសពីរ ត្រូវបានលុបបំបាត់ ហើយម៉ោងបញ្ចាំងត្រូវបានដាក់កម្រិត ឬឆ្លាស់វេនដើម្បីចៀសវាងការចាំបាច់ក្នុងការសម្រាក និងទប់ស្កាត់ការកកកុញខ្លាំងនៅចន្លោះការបញ្ចាំង។

- ☐ សន្តិសុខ និង/ឬបុគ្គលិកជាច្រើនត្រូវបានចាត់តាំងដើម្បីធ្វើឲ្យប្រាកដថាបុគ្គលិក និងអតិថិជនគោរពតាមសេចក្តីតម្រូវទាំងអស់។

C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ☐ ប្រព័ន្ធ HVAC នៅក្នុងបន្ទប់លក់សំបុត្របិទជិត និងកន្លែងលក់អាហារសម្រន់ និងបន្ទប់ទឹកគឺមានសភាពល្អ ដំណើរការធម្មតា។ ទៅតាមកម្រិតអតិបរមាដែលអាចធ្វើបាន ខ្យល់ចេញចូលត្រូវបានបង្កើន។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ បន្ទប់ទទួលភ្ញៀវ និងទីកន្លែងផ្សេងៗទៀតទាំងអស់។
- ☐ ក្រដាសសំបុត្រអាចត្រូវបានទទួលដោយបុគ្គលិក ដែលស្ថិតនៅក្នុងបន្ទប់មួយ ដោយពាក់ក្រណាត់ជាំងមុខ និងស្រោមដៃដែលប្រើហើយអាចបោះចោលបាន និងការពារដោយរបាំងសមស្រប។ សំបុត្រ ឬបង្ហាន់ដៃអេឡិចត្រូនិកអាចត្រូវបានស្កេនដោយបុគ្គលិកនៅក្នុងបន្ទប់ដែលបានការពារខាងលើ ឬដោយបុគ្គលិកស្ថិតនៅទីវាលដែលពាក់ក្រណាត់ជាំងមុខ និងស្រោមដៃដែលប្រើហើយអាចបោះចោលបាន។
- ☐ វត្ថុនិងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់នៅក្នុងបន្ទប់ទឹក ក៏ដូចជាកន្លែងយកអាហារសម្រន់ និងកន្លែងបង់ប្រាក់ (ឧ. បញ្ជរ ដៃទ្វារឬដៃកាន់ ម៉ាស៊ីនអានកាតណាទាន) ត្រូវបានសម្លាប់មេរោគរៀងរាល់ម៉ោងក្នុងអំឡុងម៉ោងធ្វើការដោយប្រើសារធាតុសម្លាប់មេរោគដែលបានអនុញ្ញាតដោយ EPA។
- ☐ ទីកន្លែងការងារ និងអគារទាំងមូលត្រូវបានសម្អាតយ៉ាងតិចជាប្រចាំថ្ងៃ ដោយបន្ទប់ទឹក និងតំបន់/វត្ថុ

ដែលបានប៉ះជាញឹកញាប់ ត្រូវបានសម្អាតញឹកញាប់ជាង។

- ☐ អតិថិជនដែលមកដល់ទីកន្លែងត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលា (លើកលែងតែពេលបរិភោគ ឬផឹក បើសិនជាអាចធ្វើបាន) ខណៈពេលនៅក្នុងទីកន្លែង ឬនៅលើទីធ្លានៃទីកន្លែង។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រប៉ុណ្ណោះទើបត្រូវបានលើកលែងពីការពាក់នេះ។ ដើម្បីគាំទ្រសុវត្ថិភាពបុគ្គលិករបស់អ្នកនិងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខឲ្យភ្ញៀវដែលមកដល់ដោយគ្មានវា។
- ☐ ការត្រួតពិនិត្យរោគសញ្ញាត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចនឹងចូលក្នុងទីកន្លែង។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យទាក់ទងនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងអការក្រុនក្តៅឬក្រុនរងា។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាការចុះឈ្មោះចូលតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយប្តេជ្ញាថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ☐ អតិថិជនដែលមកដល់ទីកន្លែងជាមួយកូនៗត្រូវតែធ្វើឲ្យប្រាកដថាកុមារមិនចាកចេញពីរថយន្តរបស់ខ្លួនតែម្នាក់ឯង។ បើសិនជាកុមារចាំបាច់ត្រូវតែទៅបន្ទប់ទឹក ឬទៅជាមួយមនុស្សធំនៅកន្លែងលក់អាហារសម្រន់ មនុស្សធំដែលទៅជាមួយត្រូវតែធ្វើឲ្យប្រាកដថា កុមារស្ថិតនៅជិតខ្លួន មិនប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងពាក់ក្រណាត់ជាំងមុខ បើសិនជាគ្រប់អាយុ។
- ☐ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់អតិថិជននៅ ឬជិតច្រកចូលបន្ទប់ទឹក និងកន្លែងលក់អាហារសម្រន់។
- ☐ ឧបករណ៍សម្រាប់បង់ប្រាក់ ប៊ិច ស្ទីឡូ (Styluses) ទាំងអស់ត្រូវបានសម្លាប់មេរោគ បន្ទាប់ពីប្រើប្រាស់ម្តងៗដោយមនុស្សផ្សេងៗគ្នា។
- ☐ ស្រេចចិត្ত - ពិពណ៌នាពីវិធានការណ៍គ្រប់គ្រងការឆ្លងជំងឺផ្សេងទៀត៖

D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណជន

- ☐ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ណែនាំដល់អតិថិជនពីរបៀបទិញសំបុត្រតាមអនឡាញ និងគោលការណ៍ផ្សេងៗដែលទាក់ទងនឹងភស្តុតាងនៃការទិញនៅទីកន្លែង។
- ☐ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកដំណើរការ ការតម្រូវឲ្យប្រើរបាំងមុខ គោលការណ៍ទាក់ទងនឹងការបញ្ជាទិញជាមុន ការបង់ប្រាក់ជាមុន ការមកយកនិង/ឬការដឹកជញ្ជូនអាហារសម្រន់ និងបញ្ហាផ្សេងៗទៀត។ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងអគារ។
- ☐ ស្លាកសញ្ញាដែលអាចមើលឃើញនៅច្រកចូលក្នុងទីកន្លែង និងទីកន្លែងនានាដែលអតិថិជនតម្រង់ជួរ ជូនដំណឹងដល់អតិថិជនអំពីសេចក្តីតម្រូវដែលទាក់ទងនឹងការការពារកំលាតរាងកាយ និងការគ្រប់គ្រងការឆ្លងជំងឺ ដែលរួមមាន៖
  - ☐ ការហាមឃាត់ការប្រមូលផ្តុំ ឬការមើលនៅខាងក្រៅរថយន្ត
  - ☐ លទ្ធភាពក្នុងការបញ្ជាទិញជាមុនពីតូបលក់អាហារសម្រន់៖
  - ☐ តម្រូវឲ្យប្រើក្រណាត់ជាំងមុខ នៅពេលទៅតូបលក់អាហារសម្រន់ ឬបន្ទប់ទឹក
  - ☐ តម្រូវឲ្យមនុស្សធំត្រួតពិនិត្យកូនៗរបស់ខ្លួន
  - ☐ ការអនុវត្តតាមការណែនាំរបស់បុគ្គលិកដោយក្តីគោរពទាក់ទងនឹងចំណុចខាងលើ។
- ☐ សេចក្តីប្រកាសលើអេក្រង់មុនពេលចាក់បញ្ចាំង ត្រូវបានប្រើដើម្បីពង្រឹងការយល់ដឹងរបស់អតិថិជនអំពីសេចក្តីតម្រូវដែលទាក់ទងនឹង ការការពារកំលាតរាងកាយ និងការគ្រប់គ្រងការឆ្លងជំងឺ ដូចខាងលើ។
- ☐ ម៉ឺនុយទំនិញដែលមានសម្រាប់ទិញ គឺមានរួចរាល់សម្រាប់អតិថិជនដែលមានគម្រោងទិញនៅនឹង

	កន្លែង នៅតូបលក់អាហារសម្រន់។
E.	**វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព**
☐	សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់ភ្ញៀវ/អតិថិជនត្រូវបានផ្តល់អាទិភាព។
☐	ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
☐	វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។
F.	**ការរៀបចំបណ្តោះអាសន្ន ឬពាក់កណ្តាលអចិន្ត្រៃយ៍នៅក្នុងចំណតយានយន្ត ឬទីកន្លែងផ្សេងទៀត**
☐	**ការជូនដំណឹងដល់ស្ថាប័នសុខភាពសាធារណៈ។** ស្ថាប័នដែលមានបំណងបង្កើតប្រតិបត្តិការភាពយន្ត បើកចូលនៅលើទីតាំងដែលជាធម្មតាមិនត្រូវបានប្រើសម្រាប់គោលបំណងនោះ គួរតែដាក់ស្នើផែនការលាយលក្ខណ៍អក្សរដើម្បីដោះស្រាយពីបញ្ហាសុវត្ថិភាព និងសុខភាពទាំងអស់ទៅកាន់អ៊ីមែល ehmail@ph.lacounty.gov យ៉ាងតិចណាស់ 7 ថ្ងៃជាមុន។ អង្គភាពសុខភាពបរិស្ថាន ក៏អាចតម្រូវឲ្យមានការដើរចូលពិនិត្យដើម្បីវាយតម្លៃទីតាំង និងទីកន្លែងផងដែរ។
☐	**ទ់ហ់ទីតាំង**។ ទីតាំងត្រូវតែធំល្មមដើម្បីសម្រួលដល់ចំនួនភ្ញៀវ និងយានយន្តរបស់ពួកគេដែលបានរំពឹងទុក ដោយមានកំលាត 6 ហ្វីតឬឆ្ងាយជាងនេះរវាងរថយន្តទាំងអស់ ទីធ្លាគ្រប់គ្រាន់សម្រាប់បន្ទប់ទឹក ស្ថានីយ៍លាងដៃ កន្លែងបញ្ជាំងភាពយន្ត និងកន្លែងបុគ្គលិកសម្រាក។
☐	**ការគ្រប់គ្រងបរិវេណ និងអ្នកចូលរួម**។ បង្កើតផែនការដែលកំណត់ពីសមត្ថភាពផ្ទុកអតិបរមា ដើម្បីគោរពតាមការវិតបន្ទឹងផ្នែកសុខភាពសាធារណៈដោយធានាបាននូវច្រកចេញចូលដែលមានការគ្រប់គ្រង។
☐	**ម្ហូបអាហារ**។ សេវាកម្មម្ហូបអាហារទាំងឡាយ ត្រូវតែមកពីភោជនីយដ្ឋាននៅនឹងកន្លែង ឬទីផ្សារដែលបានអនុញ្ញាតដោយអង្គភាពសុខភាពបរិស្ថាន។ គេអាចទិញនិងមកយកម្ហូបអាហារនៅនឹងកន្លែង ឬបញ្ជាទិញតាម រយ:សេវាដឹកជញ្ជូនភាគីទីបី និងដឹកជញ្ជូនទៅដល់យានយន្តរបស់អតិថិជន។ ទីកន្លែងម្ហូបអាហារទាំងនេះ ត្រូវតែគោរពតាមពិធីការបើកឡើងវិញជាធរមាន។ អ្នកចូលរួមអាចយកម្ហូបអាហាររបស់ខ្លួនមកបាន។ តូបលក់អាហារសម្រន់បណ្តោះអាសន្ន តូបលក់ដែលមិនមានការអនុញ្ញាត និងទីកន្លែងម្ហូបអាហារផ្សេងទៀត (ឧ. ម្ហូបអាហារដែលបានផ្ទត់ផ្ទង់ រថយន្តលក់ម្ហូបអាហារ ១ទេះលក់ម្ហូបអាហារ) មិនត្រូវបានអនុញ្ញាតទេ។
☐	**បន្ទប់ទឹក និងការលាងដៃ**។ បើសិនជាមិនមានបន្ទប់ទឹក ឬស្ថានីយ៍លាងដៃ ឬមានមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់អ្នកចូលរួមដែលបានរំពឹងទុក គេត្រូវតែផ្តល់បន្ទប់ទឹក និងស្ថានីយ៍លាងដៃចល័ត។ ត្រូវតែមានបង្គន់ 1 និងស្ថានីយ៍លាងដៃ 2 ក្នុងអ្នកចូលរួម 100 នាក់។
G.	**ការប្រគុំតន្ត្រី និងការសម្តែងផ្ទាល់**
☐	បុគ្គលិក ក្រុមថត តន្ត្រីករ និងអ្នកសម្តែងទាំងអស់ត្រូវបានណែនាំឲ្យពាក់របាំងមុខ និងរក្សាគំលាតយ៉ាងតិចប្រាំមួយ (6) ហ្វីតពីគ្នានៅគ្រប់ពេលវេលាទាំងអស់ លើកលែងនៅពេលកិច្ចការជាក់លាក់ទាមទារឲ្យធ្វើការងារជិតគ្នាជាងនេះ។
☐	កិច្ចសន្យា ស្គ្រីប ក្រដាសតន្ត្រី និងឯកសារផ្សេងៗទៀតទាំងអស់ ដែលជាធម្មតាត្រូវបានចែករំលែក គឺត្រូវបានចែកចាយតាមបែបឌីជីថល ឬបោះពុម្ពនិងកំណត់ជាបុគ្គលសម្រាប់ក្រុមថត តន្ត្រីករ និងអ្នកសម្តែងដើម្បីចៀសវាងការចែករំលែក។
☐	នៅគ្រប់ពេលដែលអាចធ្វើបាន មនុស្សគ្រប់គ្នាគួរប្រើប្រាស់ឧបករណ៍ផ្ទាល់ខ្លួន (ដូចជាកាស់ មីក្រូហ្វូន ខនសូល) គ្រឿងផ្ទត់ផ្ទង់ ។ល។ បើសិនជាចាំបាច់ត្រូវតែចែករំលែកឧបករណ៍ គេគួរធ្វើអនាម័យវាបន្ទាប់ពីការប្រើប្រាស់ម្តងៗ។
☐	គេត្រូវតែផ្តល់គ្រឿងសម្គាល់គំលាត ដើម្បីចង្អុលបង្ហាញពីការរក្សាគំលាតសង្គមបានគ្រប់គ្រាន់។ មីក្រូហ្វូន ខនសូល និងឧបករណ៍ផ្សេងទៀតត្រូវតែរៀបចំឡើងដើម្បីសម្របសម្រួលឲ្យមានការរក្សាគំលាតសង្គម។
☐	តន្ត្រីករ និងអ្នកចម្រៀងទាំងអស់ដែលធ្វើការសម្តែងដែលពួកគេមិនអាចពាក់របាំងមុខបាន (ឧ. អ្នកលេងឧបករណ៍ដែលប្រើខ្យល់ ឬផ្លុំ អ្នកចម្រៀង) គួររក្សាគំលាតសង្គមយ៉ាងតិច 8 ហ្វីតក្នុងអំឡុងការហាត់សមនិងការសម្តែងនានា។ ម្យ៉ាងវិញទៀត បុគ្គលទាំងនេះគួរត្រូវបានបំបែកពីគ្នាដោយប្រើកញ្ចក់ Plexiglass ឬរបាំងផ្សេង ទៀត។
☐	បុគ្គលទាំងនោះត្រូវតែមកដល់ដោយបានធ្វើសក់ និងតុបតែងមុខរួចជាស្រេច បើចាំបាច់។

- ការសម្តែងផ្ទាល់ទាំងអស់ ត្រូវតែគោរពតាមពិធីការស្តីពីតន្ត្រី ភាពយន្ត និងផលិតកម្មទូរទស្សន៍ឧបសម្ព័ន្ធ J។

វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។

អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖

ឈ្មោះទំនាក់ទំនងអាជីវកម្ម៖ _____ **លេខទូរស័ព្ទ៖** _____

កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖ _____